# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Dec-2011, 14:49
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

## ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំទទួលឯកសារថ្មីពីរ

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

**ជំនួយការ៖**

លោកស្រី សេង សុជាតា

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Clémence WITT

កញ្ញា Mathilde CHIFFERT

កញ្ញា អ៊ូច ស្រីផាត់

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្ដីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## I- សេចក្តីផ្តើម

១. កាលពីថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានជូនដំណឹងដល់ភាគីនានា អំពីសំណើសុំការអនុញ្ញាតិពីអង្គជំនុំជម្រះសាលាដំបូង ដើម្បីឲ្យខ្លួនអាចដាក់ឯកសារថ្មីពីរ (ខ្សែវីដេអូមួយ និងសៀវភៅមួយក្បាល) ចូលទៅក្នុងសំណុំរឿង។ សំណើរបស់សហព្រះរាជអាជ្ញាត្រូវបានដាក់ដោយយោងតាមវិធាន ៩២ និង វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[1]។

២. លោក ខៀវ សំផន សូមជំទាស់នឹងសំណើយឺតយ៉ាវនេះ ហើយស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាបដិសេធសំណើនេះចោល ដោយហេតុថាសំណើនេះមិនបំពេញលក្ខណៈវិនិច្ឆ័យគតិយុត្តិ ដូចបានតម្រូវ។

## II- ការពិភាក្សា

៣. កាលពីពេលថ្មីៗកន្លងទៅនេះ អង្គជំនុំជម្រះសាលាដំបូងបានរំឮកថា លក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[2] "មានភាពតឹងតែងហួសហេតុ" ពីព្រោះវិធាននេះតម្រូវឲ្យបង្ហាញថា *"ទោះបីជាមានការខ្នះខ្នែងអស់ពីលទ្ធភាពយ៉ាងណាក៏ដោយ"* ក៏ឯកសារមិនអាចត្រូវ

---

[1] ការបង្ហាញជូនរបស់សហព្រះរាជអាជ្ញា អំពីការធ្វើសម្ភាសន៍ជាមួយ ខៀវ សំផន និងសៀវភៅដែលមានចំណងជើងថា "នៅពីក្រោយវាលពិឃាត៖ មេដឹកនាំខ្មែរក្រហមម្នាក់ និងជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះជាច្រើនរបស់គាត់" ដោយលោក GINA CHON និងលោក ថេត សម្បត្តិ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E152 ("សំណើរបស់សហព្រះរាជអាជ្ញា")។ ដោយសារសំណើនេះត្រូវបានជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរ នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១១ ចម្លើយតបនេះត្រូវបានដាក់ជាភាសាបារាំង។

[2] "ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភ័ស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់លាស់។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬភ័ស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ"។

បានផ្តល់ជូនតាមកាលកំណត់។ លើសពីនេះទៅទៀត ភាគីស្នើសុំត្រូវបង្ហាញថាការទទួលយកឯកសារយឺតយ៉ាវ *"មានសារៈសំខាន់ជាសារវ័ន្ត"* ដើម្បីផលប្រយោជន៍នៃយុត្តិធម៌[3]។

៤. ក្នុងរឿងក្តី ឌុច អង្គជំនុំជម្រះបានអះអាងរួចមកហើយថា *"ដើម្បីប្រកាសថាឯកសារថ្មីអាចទទួលយកបាន ឯកសារថ្មីនោះត្រូវតែ (...) បង្ហាញហេតុផលថាមិនមានលទ្ធភាពគោរពតាមកាលកំណត់នោះបាន ហើយឯកសារនោះត្រូវបានដាក់ឲ្យបានឆាប់រហ័សបំផុត ក្រោយកាលបរិច្ឆេទផុតកំណត់ក្នុងកាលៈទេសៈពិសេសដែលភាគីស្នើសុំស្វះស្វែងដាក់ឯកសារបន្ទាប់ពីផុតកាលកំណត់"*[4]។ ក្រៅពីនេះទៀត អង្គជំនុំជម្រះធានាថា *"មិនមានហេតុផលបង្ហាញថាការយឺតយ៉ាវក្នុងការដាក់ភស្តុតាង គឺជាទង្វើដោយចេតនា"*[5]។

៥. ក្នុងករណីនេះ សហព្រះរាជអាជ្ញាមិនបានបង្ហាញថា ខ្លួនបានខ្វះខ្នែងអស់ពីលទ្ធភាព ហើយមិនអាចគោរពតាមពេលវេលា ដែលកំណត់ដោយអង្គជំនុំជម្រះឡើយ។

**ក. ឯកសារទីមួយ៖ ខ្សែវីដេអូ**

៦. សហព្រះរាជអាជ្ញាអះអាងថាបានរកឃើញខ្សែវីដេអូសម្ភាសន៍ជាមួយលោក ខៀវ សំផន នៅក្នុងអ៊ីនធឺណិត នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១១។ សហព្រះរាជអាជ្ញាយល់ឃើញថា ខ្សែវីដេអូមួយនេះទំនងជាដាក់ផ្សាយក្នុងអ៊ីនធឺណិត ដោយបុគ្គលមួយរូបដែលអះអាងថាខ្លួនគឺជាខៀវ សំផន។

៧. សហព្រះរាជអាជ្ញាមិនបានបញ្ជាក់អំពីកាលបរិច្ឆេទនៃកិច្ចសម្ភាសន៍ទាំងនោះ ឬកាលបរិច្ឆេទដាក់ផ្សាយខ្សែវីដេអូនេះក្នុងអ៊ីនធឺណិត ឬអាសយដ្ឋានវែបសាយត៍ដែលខ្សែវីដេអូនោះត្រូវបានរកឃើញនោះឡើយ។ សហព្រះរាជអាជ្ញាបានត្រឹមតែអះអាងថា ខ្សែវីដេអូនេះមិនអាចរកបាន នៅមុនថ្ងៃទី

---

[3] បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់ការដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E131/1 ទំព័រ ៦។

[4] សេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃភស្តុតាងថ្មី និងសេចក្តីណែនាំដល់ភាគីទាំងអស់ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ ឯកសារ D288/6.5/10/2 កថាខណ្ឌ ៦។

[5] *ដូចខាងលើ* កថាខណ្ឌ ១២។

២៧ ខែ មិថុនា ឆ្នាំ ២០១១[6] ដោយមិនបានផ្តល់ព័ត៌មានសម្រាប់ពិនិត្យផ្ទៀងផ្ទាត់អ្វីទាំងអស់។ តាមពិត ការអះអាងបែបនេះមិនអាចបង្ហាញថា សហព្រះរាជអាជ្ញាមិនអាចគោរពតាមពេលវេលាដែលកំណត់ដោយអង្គជំនុំជម្រះនោះទេ (សម្រាប់ជាការចងចាំ៖ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១១)[7]។

៨. លើសពីនោះទៀត សហព្រះរាជអាជ្ញាប្រកាសថាបានរកឃើញខ្សែវីដេអូនេះនៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ប៉ុន្តែ ទើបតែផ្តល់ដំណឹងនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១១ គឺជាងមួយខែក្រោយមក។

## ខ. ឯកសារទីពីរ៖ សៀវភៅ

៩. សហព្រះរាជអាជ្ញាអះអាង កាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១ ថាបានរកឃើញសៀវភៅមួយក្បាល និពន្ធដោយ Gina Chon និងថេត សម្បត្តិ មានចំណងជើងថា "*នៅពីក្រោយវាលពិឃាត៖ មេដឹកនាំខ្មែរក្រហមម្នាក់ និងជនរងគ្រោះម្នាក់ ក្នុងចំណោមជនរងគ្រោះជាច្រើនរបស់គាត់*" (*Behind the Killing Fields: a Khmer Rouge Leader and One of His Victims*)។ សហព្រះរាជអាជ្ញាចង្អុលបង្ហាញថា សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយ នៅឆ្នាំ២០១០ ហើយត្រូវបានបណ្ណាល័យ អ.វ.ត.ក ទិញបាន នៅខែ សីហា ឆ្នាំ ២០១១[8]។

១០. ដោយសារតែការទិញសៀវភៅមួយក្បាលដោយបណ្ណាល័យ អ.វ.ត.ក ពិតជាមិនអាចឲ្យគិតកាលកំណត់ស្របច្បាប់អប្បបរមាក្នុងរឿងក្តីនេះ ជាក់ស្តែងណាស់ សៀវភៅនេះមានតាំងពីឆ្នាំ២០១០មកម្ល៉េះ ហើយគ្មានលេសអ្វីដែលសហព្រះរាជអាជ្ញាខកខានមិនបានបំពេញកាតព្វកិច្ចខ្នះខ្នែងរបស់ខ្លួន ពាក់ព័ន្ធនឹងបញ្ហានេះបានទេ។

---

[6] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣។

[7] ពេលវេលាកំណត់ដំបូងគឺថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១១ ហើយបន្ទាប់ពីការប្រកាសពីការឈប់សម្រាករបស់តុលាការរួចមក ពេលវេលាកំណត់ត្រូវបានលើករហូតដល់ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១៖ ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារ E9 ; អនុស្សរណៈពាក់ព័ន្ធនឹងការឈប់សម្រាករបស់ចៅក្រមក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១ ឯកសារ E68។

[8] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥។

១១. ម្យ៉ាងវិញទៀត ទោះបីជាកាលបរិច្ឆេទទិញសៀវភៅនេះដោយបណ្ណាល័យត្រូវបានគិតក៏ដោយ ក៏ការទិញត្រូវបានធ្វើឡើង បួនខែមុនពេលរកឃើញតាមការអះអាងរបស់សហព្រះរាជអាជ្ញា។

១២. ទន្ទឹមនឹងនេះ អង្គជំនុំជម្រះនឹងកត់សម្គាល់ឃើញថា តាមអ៊ីមែលចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១១ បុគ្គលិកទាំងអស់របស់ អ.វ.ត.ក (រួមទាំងសហព្រះរាជអាជ្ញាផងដែរ) ត្រូវបានជូនដំណឹងអំពីការទិញសៀវភៅនេះ ដោយបណ្ណាល័យ អ.វ.ត.ក[9]។

១៣. ជាការសន្និដ្ឋាន សហព្រះរាជអាជ្ញាមិនបានបង្ហាញថាខ្លួនបានខិតខំខ្នែងអស់ពីលទ្ធភាព ឬខ្លួនមិនអាចគោរពតាមពេលវេលាដែលកំណត់ដោយអង្គជំនុំជម្រះ ឬដាក់ឯកសារថ្មីទាំងពីរនេះឲ្យបានឆាប់រហ័សបំផុត ក្រោយកាលបរិច្ឆេទផុតកំណត់ នោះទេ។

១៤. លើសពីនេះទៅទៀត សហព្រះរាជអាជ្ញាក៏មិនបានបង្ហាញផងដែរថា ការទទួលយកឯកសារថ្មីពីរនេះមានសារៈសំខាន់ជាសារវ័ន្ត ដើម្បីផលប្រយោជន៍យុត្តិធម៌ ឬឯកសារពីរនេះបំពេញលក្ខណៈវិនិច្ឆ័យភាពជាប់ពាក់ព័ន្ធ ភាពគួរឲ្យជឿជាក់បាន និងយថាភាព ដែលកំណត់ដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង[10] នោះដែរ។ លោក ខៀវ សំផន នឹងបញ្ជាក់បន្ថែមនូវទឡ្ហីករណ៍លើចំណុចទាំងអស់នេះ ដោយផ្ទាល់មាត់ នៅពេលក្រោយ ប្រសិនបើអាច។

## អាស្រ័យហេតុនេះ

១៥. លោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **បដិសេធ**សំណើរបស់សហព្រះរាជអាជ្ញា។

---

[9] អ៊ីមែល ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១១ ម៉ោង ១០ និង ៥៨ នាទី មានចំណងជើងថា « *New Books arrival* » [សៀវភៅថ្មីមកដល់] មានភ្ជាប់ជាឧបសម្ព័ន្ធ។

[10] សេចក្តីជំទាស់មិនទទួលយកបញ្ជីឯកសារ ដែលដាក់ដោយភាគីផ្សេងទៀត សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង (ពីថ្ងៃទី ២៨ ខែ វិច្ឆិកា ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១) ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E131/6។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Arthur VERCKEN<br><br>មេធាវី Jacques VERGÈS | ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |